

# ក្រមសីលធម៌

## ភាពសុចរិតនិងការប្រព្រឹត្តប្រកបដោយសីលធម៌

BUILDING TRUST

# មាតិកា

**វិធានស្តីពីក្រមសីលធម៌ពាណិជ្ជកម្ម** **៦**

១. អនុវត្តន៍តាមច្បាប់ ៦

២. គ្មានការស៊ីសំណូក គ្មានអំពើពុករលួយ ៦

៣. អំណោយ ការអញ្ជើញកម្សាន្ត និងប្រទានកម្ម ៧

៤. ការប្រកួតប្រជែងដោយស្មោះត្រង់ ៨

៥. ជៀសវាងទំនាស់ផលប្រយោជន៍ ៩

៦. គ្មានការជួញដូរដោយប្រើព័ត៌មានផ្ទៃក្នុង ៩

៧. ការការពារសុវត្ថិភាពទិន្នន័យ និងរក្សាការសម្ងាត់ ១០

៨. ការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Sika ១១

៩. សិទ្ធិមនុស្ស និងបទដ្ឋានការងារ៖ លក្ខខណ្ឌការងារប្រកបដោយសមភាព គ្មានការបៀតបៀន គ្មានការរើសអើង ១១

១០. ការពារសុខភាព សុវត្ថិភាព និងបរិស្ថាន ១២

១១. ដៃគូអាជីវកម្ម ១៣

១២. ការនាំចូល និងការនាំចេញ ១៣

១៣. ការលាងលុយកខ្វក់ ១៣

**វិធាននៃការប្រតិបត្តិ** **១៤**

១៤. ធានាឲ្យបាននូវការអនុលោមតាមក្រមនេះ ១៤

១៥. រក្សាតម្លាភាពពេញលេញ និងការសម្តែងមតិ ១៤

១៦. ធ្វើជាគំរូ ១៥

១៧. មិនត្រូវធ្វើអ្វីរំលងវិធានទាំងនេះ ១៦

១៨. បើមានមន្ទិលសង្ស័យ ត្រូវសួរ ១៦

១៩. គោលការណ៍ទូទៅ៖ ច្បាប់ទស្សនាវដ្តី ១៦

២០. អនុវត្តគោលការណ៍ភ្នែកបួន ១៦

២១. សំណួរ និងយោបល់ ១៧



# ក្រមសីលធម៌

គោរពជូនមិត្តទាំងអស់ជាទីស្រលាញ់

Sika ឈរលើគោលការណ៍ **ការកសាងទំនុកចិត្ត** ដែលផ្តោតសំខាន់លើអាកប្បកិរិយាប្រកបដោយសីលធម៌ និងសុចរិត ។

សហការី អតិថិជន អ្នកផ្គត់ផ្គង់ និងម្ចាស់ភាគហ៊ុនរបស់យើងសុទ្ធតែពឹងផ្អែកលើសុចរិតធម៌របស់យើង។ ការប្រព្រឹត្តប្រកបដោយសីលធម៌របស់យើង តំណាងឱ្យមូលដ្ឋានគ្រឹះនៃកេរ្តិ៍ឈ្មោះដ៏ល្អរបស់ Sika និងបង្ហាញពីភាពជោគជ័យយូរអង្វែងរបស់ក្រុមហ៊ុនយើង។

ការបង្កើតក្រមសីលធម៌ មានគោលបំណងលើកកម្ពស់សុចរិតធម៌ និងការប្រព្រឹត្តប្រកបដោយសីលធម៌នៅគ្រប់ប្រតិបត្តិការរបស់ Sika ទូទាំងពិភពលោក។ ក្រមសីលធម៌នេះពន្យល់លំអិតអំពី **គុណតម្លៃ និងគោលការណ៍នានា** របស់ Sika ដែលជាមូលដ្ឋានគ្រឹះនៃឯកវប្បធម៌របស់យើង។ Sika មិនទទួលយកការបំពានច្បាប់ ឬការបំពានក្រមសីលធម៌នេះ ព្រោះយើងប្រកាន់គោលជំហរគ្មានការអត់អោន ចំពោះអាកប្បកិរិយាដែលគ្មានក្រមសីលធម៌។

ជាមួយនឹងក្រមសីលធម៌វិជ្ជាជីវៈដែលបានកែសម្រួលនេះ យើងក៏គូសបញ្ជាក់ពីការប្តេជ្ញាចិត្ត យ៉ាងមុតមាំរបស់យើងចំពោះការអភិវឌ្ឍប្រកបដោយចីរភាព សិទ្ធិមនុស្ស និងការការពារបរិស្ថានផងដែរ។

ដើម្បីអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈនេះ គឺយើងត្រូវមានការទទួលខុសត្រូវផ្ទាល់ខ្លួន ដោយមិនគិតពីតួនាទី កម្រិតឋានានុក្រម ឬកន្លែងធ្វើការរបស់អ្នកឡើយ។ ទោះអ្នកធ្វើអ្វីឲ្យ Sika ក៏ដោយ ត្រូវអនុវត្តតាមពាក្យពេចន៍ និងស្មារតីនៃក្រមនេះ។ ធ្វើជាគំរូក្នុងការដឹកនាំនិងបំផុសទឹកចិត្តអ្នកដទៃឱ្យមានស្មារតីជាអ្នកដឹកនាំដូចគ្នា!

សូមអរគុណក្នុងការចូលរួម និងការរួមចំណែកដ៏មានសារៈសំខាន់របស់អ្នកចំពោះភាពជោគជ័យរបស់ Sika។



Thomas Hasler
ថូម៉ាស ហាស្លឺ



Thierry Vanlancker
ប្រធានក្រុមប្រឹក្សាភិបាល

Baar ខែមេសា ឆ្នាំ ២០២៤

# ភាពសុចរិត និងការប្រតិបត្តិក្រមសីលធម៌

យើងធ្វើអ្វីដោយអនុលោមទៅតាមច្បាប់

ក្នុងកាលៈទេសៈណាក៏ដោយ យើងប្រកាន់លើភាពត្រឹមត្រូវ

យើងអនុវត្តបទដ្ឋានក្រមសីលធម៌ខ្ពស់ ក្នុងការងាររបស់យើង

យើងធានាឲ្យបាននូវការប្រតិបត្តិតាមគោលការណ៍ច្បាប់ទាំងនេះ







**ការប្រតិបត្តិតាមក្រមសីលធម៌នេះគឺជាការទទួលការខុសត្រូវ ផ្ទាល់ខ្លួនរបស់មនុស្សទាំងអស់ដែលធ្វើការងារជាមួយស៊ីកា**







## វិធានស្តីពីក្រមសីលធម៌ពាណិជ្ជកម្ម

### ១. អនុវត្តន៍តាមច្បាប់

- អនុវត្តច្បាប់ឱ្យបានតឹងរ៉ឹង និងបទបញ្ញត្តិដែលអាចអនុវត្តបានលើអាជីវកម្មរបស់យើងទាំងអស់គ្នា។
- ត្រូវគោរពយ៉ាងតឹងរ៉ឹងតាមក្រមសីលធម៌វិជ្ជាជីវៈនេះ និងបទបញ្ជាផ្ទៃក្នុងផ្សេងៗទៀត ទោះបីជាតឹងរ៉ឹងជាងច្បាប់ដែលមានជាធរមានក៏ដោយ។

*ការអនុលោមពេញលេញតាមច្បាប់ និងបទបញ្ញត្តិដែលត្រូវអនុវត្ត គឺជាក្របខ័ណ្ឌសម្រាប់សកម្មភាពទាំងអស់របស់យើង។ លើសពីនេះ ក្រមសីលធម៌នេះកំណត់នូវវិធានដែលអាចនឹងតឹងរ៉ឹងជាងច្បាប់ដែលមានជាធរមាន។ ដូចគ្នានេះដែរ បទបញ្ជាផ្ទៃក្នុងបន្ថែមទៀតក៏ត្រូវតែគោរពតាមដែរ។*

### ២. គ្មានការស៊ីសំណូក គ្មានអំពើពុករលួយ

- មិនត្រូវជូនសគុណ (ជាសាច់ប្រាក់ ដំណើរកម្សាន្ត អំណោយ) ក្នុងគោលបំណងជះឥទ្ធិពលលើការសម្រេចចិត្តរបស់បុគ្គលណាម្នាក់ (ឧ. ផ្តល់អំណោយដើម្បីរក្សា ឬទទួលបានអាជីវកម្ម) ឬដើម្បីទទួលបានអត្ថប្រយោជន៍ដែលមិនត្រឹមត្រូវ (ឧ. លិខិតអនុញ្ញាតដែល Sika មិនមានសិទ្ធិទទួលបាននោះទេ)។
- មិនត្រូវទទួលសគុណ (សាច់ប្រាក់ ដំណើរកម្សាន្ត អំណោយ) ដែលជះឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នក ឬនាំឱ្យអ្នកផ្តល់អត្ថប្រយោជន៍ខុសពីគោលការណ៍របស់ក្រុមហ៊ុន (ឧ. ការបញ្ចុះតម្លៃដល់ដៃគូអាជីវកម្មដែលមិនមានលក្ខខណ្ឌគ្រប់គ្រាន់)។

*Sika ប្តេជ្ញាប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយគ្រប់រូបភាព។  Sika ហាមឃាត់និយោជិត ភ្នាក់ងារ ហើយនឹងភាគីទីបីរបស់ខ្លួន មិនឲ្យចូលរួមក្នុងអំពើសូកប៉ាន់គ្រប់ប្រភេទ។ ការសូកប៉ាន់ និងការប្រព្រឹត្តអំពើពុករលួយអាចកើតមានគ្រប់ទម្រង់។ វាអាចជាសាច់ប្រាក់ ប៉ុន្តែក៏អាចជាសគុណផ្សេងទៀតដែរ (ដំណើរកម្សាន្ត អំណោយប្រភេទណាមួយ)។ ការសូកប៉ាន់ត្រូវបានធ្វើឡើងដើម្បីបង្វែរការសម្រេចចិត្តរបស់អ្នកទទួលសំណូក ក្នុងគោលបំណងធ្វើអោយម្ចាស់សំណូក ឬ អង្គភាពដែលផ្តល់សំណូកទទួលបានអត្ថប្រយោជន៍ពិសេសដែលមិនត្រឹមត្រូវ។*
*វាមិនសំខាន់ទេដែលថាភាគីម្ខាងទៀតជានរណា (អាចជា រាជរដ្ឋាភិបាល ក្រុមហ៊ុន ឬបុគ្គល)។ លើកលែងតែការផ្តល់អំណោយ និងការអញ្ជើញកម្សាន្តធម្មតាដែលគ្មានគោលបំណងសម្លឹងឃើញផលប្រយោជន៍មិនត្រឹមត្រូវណាមួយ (អាននៅចំនុចទី៣) បើទោះបីជាប្រយោជន៍នោះធំឬតូចក៏ដោយ វានៅតែជាការសូកប៉ាន់ឬអំពើពុករលួយដែលត្រូវបានហាមឃាត់ជាដាច់ខាត។*

### ៣. អំណោយ ការអញ្ជើញកម្សាន្ត និងប្រទានកម្ម

- អាចជូន ឬទទួលអំណោយ និងការកម្សាន្តណាដែលស្របច្បាប់ សមហេតុផល តម្លៃមធ្យម និងស្របតាមគោលការណ៍ស្តីពីអំណោយ និងការកម្សាន្តរបស់ក្រុមហ៊ុន Sika តែប៉ុណ្ណោះ។
- ការឧបត្ថម្ភ និងប្រទានកម្មសប្បុរសធម៌ត្រូវបានអនុញ្ញាត ប្រសិនបើអនុលោមតាមគោលការណ៍ស្តីពីអំណោយ និងការអញ្ជើញកម្សាន្តរបស់ក្រុមហ៊ុន Sika ប្រចាំតំបន់របស់អ្នក។
- ការប្រើមូលនិធិ Sika ដើម្បីជួយអ្នកនយោបាយ បេក្ខជននយោបាយ ឬគណបក្សនយោបាយគឺត្រូវបានហាមឃាត់។ ការបរិច្ចាគសម្រាប់យុទ្ធនាការនយោបាយដែលគាំទ្រយុទ្ធសាស្ត្រ ឬសកម្មភាពអាជីវកម្មរបស់ Sika ចាំបាច់ត្រូវមានការយល់ព្រមពីអ្នកគ្រប់គ្រងសម្ព័ន្ធក្រុមហ៊ុន។

*នៅគ្រប់ប្រទេស និងទីផ្សារទាំងអស់ អំណោយ និងការអញ្ជើញកម្សាន្តដែលសមស្រប (អាហារ ព្រឹត្តិការណ៍កីឡា ឬវប្បធម៌។ល។) គឺជាការអនុវត្តអាជីវកម្មធម្មតា។ វានឹងក្លាយជាសំណូក ប្រសិនបើវាមានគោលបំណងជះឥទ្ធិពលលើការសម្រេចចិត្តរបស់បុគ្គលដែលជាអ្នកទទួល។ ការអញ្ជើញឲ្យចូលរួមដំណើរកម្សាន្ត ឬព្រឹត្តិការណ៍ច្រើនថ្ងៃ ក៏ដូចជាអំណោយ និងការកម្សាន្តដែលផ្តល់អោយមន្ត្រីសាធារណៈឆ្លុះបញ្ចាំងពីហានិភ័យជាពិសេស។ ក្រុមហ៊ុនទាំងអស់ត្រូវតែប្រកាន់យកគោលការណ៍ស្តីពីអំណោយ និងការអញ្ជើញកម្សាន្តថ្នាក់តំបន់ ដែលកំណត់កម្រិតនៃការយល់ព្រមដែលទាមទារ និងស្របតាមគោលគោលការណ៍គំរូពីថ្នាក់គណៈគ្រប់គ្រងជាន់ខ្ពស់ (Corporate)។*



## ៤. ការប្រកួតប្រជែងដោយស្មោះត្រង់

- អនុវត្តដោយតម្រង់ឆ្ពោះទៅរកលទ្ធផលការងារ និងប្រព្រឹត្តដោយយុត្តិធម៌ក្នុងទីផ្សារ ទាំងជាមួយអតិថិជន និង អ្នកផ្គត់ផ្គង់។
- គ្មានការពិភាក្សា ការព្រមព្រៀង ឬការសហការក្នុងរូបភាពណាក៏ដោយជាមួយគូប្រកួតប្រជែង មិនថាទៅលើយុទ្ធសាស្ត្រ តម្លៃ ទីផ្សារ អតិថិជន ផលិតផល ផលិតកម្ម ឬព័ត៌មានផ្សេងទៀតដែលអាចធ្វើឲ្យប៉ះពាល់ដល់ភាពនឹងនរបស់ទីផ្សារ។
- មិនត្រូវកំណត់តម្លៃលក់បន្តទៅអោយអតិថិជនរបស់ Sika
- ត្រូវពិនិត្យជាមុននូវកិច្ចសន្យាសំខាន់ៗទាំងឡាយ (ឧ. ភាពផ្តាច់មុខ មិនប្រកួតប្រជែង ការបណ្តាក់ទុនរួមគ្នា) ជាមួយទីប្រឹក្សាច្បាប់ក្នុងតំបន់ ឬទីប្រឹក្សាច្បាប់របស់ក្រុមហ៊ុន។
- កុំបំពានដោយប្រើជំហរឧត្តមភាពលើទីផ្សារ (ប្រើអំណាចលើទីផ្សារ)។

*យើងរំពឹងថាការអនុវត្តច្បាប់ ត្រូវបានអនុលោមយ៉ាងពេញលេញទៅតាមច្បាប់ដែលពាក់ព័ន្ធនឹងការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម (cartel and antitrust law)។ ជាពិសេស ច្បាប់ទាំងនេះរួមបញ្ចូលចំពោះ គ្រប់ការពិភាក្សា ឬការព្រមព្រៀងជាមួយគូប្រកួតប្រជែងលើតម្លៃ ឬព័ត៌មានផ្សេងៗដែលអាចប៉ះពាល់ដល់ភាពនឹងនរបស់ទីផ្សារ។ ហើយផ្តោតពិសេសទៅលើការជួបជុំក្រៅផ្លូវការ សន្និសីទ ការតាំងបង្ហាញពាណិជ្ជកម្ម និងការប្រជុំនៃសមាគមពាណិជ្ជកម្ម ឬនៅក្នុងការពិភាក្សា ពាក់ព័ន្ធនឹងឱកាសក្នុងការទិញយក ឬគ្រប់គ្រងអាជីវកម្មណាមួយ។ ចំពោះទំនាក់ទំនងជាមួយការប្រគួតប្រជែងដែលស្ថិតក្នុងវិសាលភាពច្បាប់កំណត់ ត្រូវតែស្ថិតក្រោមការមើលខុសត្រូវពីអ្នកគ្រប់គ្រងទូទៅនិងត្រូវកត់ត្រាទុកឲ្យបានត្រឹមត្រូវ។*



## ៥. ជៀសវាងទំនាស់ផលប្រយោជន៍

- ជៀសវាងស្ថានភាពដែលអាចបង្កើតទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍គ្រួសារ និង  ជាមួយប្រយោជន៍របស់ក្រុមហ៊ុន Sika។ ចូរបង្ហាញយ៉ាង ពេញលេញអំពីទំនាស់ទាំងនេះទៅនឹងថ្នាក់លើ។
- ជៀសវាងសកម្មភាពណាដែលប្រកួតប្រជែងជាមួយ Sika។
- មិនត្រូវប្រើប្រាស់ឱកាសអាជីវកម្មរបស់ Sika ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកឡើយ។

*ការសម្រេចចិត្តក្នុងនាមជំនួសមុខឱ្យ Sika មិនត្រូវមានឥទ្ធិពលពីប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍គ្រួសារ។ រាល់សកម្មភាពទាំងអស់ ដែលប្រឆាំងជាមួយ Sika គឺមិនត្រូវបាន អនុញ្ញាតឡើយ។*

## ៦. គ្មានការជួញដូរដោយប្រើព័ត៌មានផ្ទៃក្នុង

- មិនត្រូវប្រើព័ត៌មានសម្ងាត់ ព័ត៌មានអំពីតម្លៃ ដើម្បីជួញដូរនៅក្នុងភាគហ៊ុន សញ្ញាប័ណ្ណ ឬប័ណ្ណបំណុលរបស់ Sika ឡើយ។
- កុំចែករំលែកព័ត៌មានទៅដល់ភាគីទីបី។
- មិនត្រូវប្រើព័ត៌មានសម្ងាត់ ព័ត៌មានដែលធ្វើឲ្យប៉ះពាល់ដល់តម្លៃនៃភាគហ៊ុន សញ្ញាប័ណ្ណ ឬប័ណ្ណបំណុលផ្សេងទៀតនៃដៃគូពាណិជ្ជកម្មរបស់ Sika ឬចែករំលែកព័ត៌មានទាំងនេះជាមួយភាគីទីបី។

*ការជួញដូរដែលផ្អែកលើព័ត៌មានផ្ទៃក្នុងជាការប្រើប្រាស់ព័ត៌មានសម្ងាត់ និងឯកជនដើម្បីសម្រេចបានប្រាក់ចំណេញដែលមិនស្របច្បាប់។ ប្រការនេះគឺខុសច្បាប់នៅប្រទេសស្វីស និងនៅបណ្តាប្រទេសជាច្រើនទៀត។ ការជួញដូរដោយប្រើប្រាស់ព័ត៌មានផ្ទៃក្នុងគឺពាក់ព័ន្ធចម្បងទៅនឹងការជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុន Sika។ ប៉ុន្តែការប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដើម្បីជួញដូរភាគហ៊ុនរបស់ដៃគូពាណិជ្ជកម្មរបស់Sikaគឺមិនត្រូវបានអនុញ្ញាតនោះឡើយ។ **គោលការណ៍នៃការជួញដូរដោយប្រើប្រាស់ព័ត៌មានផ្ទៃក្នុង និង ការគ្រប់គ្រងប្រតិបត្តិការ របស់ Sika** (Insider Trading and Management Transaction Policy) ផ្តល់ការណែនាំយ៉ាងស៊ីជម្រៅ ជាពិសេសក្នុងកំឡុងពេលគ្មានការជួញដូរ។*

## ៧. ការការពារសុវត្ថិភាពទិន្នន័យ និងរក្សាការសម្ងាត់

- ការពារការសម្ងាត់ព័ត៌មានអាជីវកម្ម បច្ចេកទេស និងព័ត៌មានហិរញ្ញវត្ថុរបស់ Sika។
- នៅក្នុងក្រុមហ៊ុន Sika ការចែករំលែកព័ត៌មានសម្ងាត់ធ្វើឡើងតែលើមូលដ្ឋានចាំបាច់ដែលត្រូវដឹងតែប៉ុណ្ណោះ។
- មិនត្រូវចែករំលែកព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនទៅភាគីទីបីនោះទេ លុះត្រាតែក្រុមហ៊ុនតម្រូវសម្រាប់គោលបំណង អាជីវកម្ម និងបន្ទាប់ពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្ងាត់តែប៉ុណ្ណោះ។
- ធានានូវភាព ច្បាស់លាស់ និង សុវត្ថិភាពពេញលេញ នៃ ព័ត៌មាន សម្ងាត់របស់ក្រុមហ៊ុន Sika ដោយផ្អែកលើ**សេចក្តីណែនាំនិងគោលការណ៍សន្តិសុខសុវត្ថិភាពផ្នែកប្រព័ន្ធព័ត៌មានវិទ្យា។** (Sika Group IT security policies and directives)
- ការពារព័ត៌មានសម្ងាត់ និងទិន្នន័យផ្ទាល់ខ្លួនរបស់ភាគីទីបី និងនិយោជិតរបស់យើង។
- ត្រូវប្រាកដថាទិន្នន័យផ្ទាល់ខ្លួនដែល Sika ប្រមូលបានត្រូវបានដំណើរការដោយត្រឹមត្រូវ និងតម្លាភាព។
- គោរពតាមច្បាប់ស្តីពីការការពារទិន្នន័យជាធរមាននៅក្នុងស្រុក និងប្រកាន់ខ្ជាប់នូវគោលការណ៍ស្តីពីការការពារទិន្នន័យផ្ទៃក្នុងរបស់ Sika។

*ការការពារចំណេះដឹងទូទៅរបស់ Sika គឺសំខាន់បំផុត។ ក្នុងខណៈដែល Sika មិនគោលបំណង ក្នុងការរារាំងលំហូរព័ត៌មាន ដែលត្រូវការសម្រាប់ការអនុវត្តអាជីវកម្ម វាសំខាន់ណាស់ ក្នុងការការពារចំណេះដឹងទូទៅរបស់ Sika ពីការប្រើប្រាស់មិនត្រឹមត្រូវ។ ពួកយើងក៏ការពារដូចគ្នាចំពោះព័ត៌មានសម្ងាត់របស់ភាគីទីបី។ Sika ប្តេជ្ញាថានឹងធ្វើការការពាររាល់ទិន្នន័យឯកជន និងសុចរិតធម៌របស់និយោជិត និង ភាគីទីបីទាំងអស់។*




## ៨. ការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Sika

- ការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Sika (ឧបករណ៍ កុំព្យូទ័រ ឡាន...) ត្រូវតែមានការថែទាំ និង ក្នុងគោលបំណងបម្រើអាជីវកម្មរបស់ក្រុមហ៊ុន បើពុំនោះទេត្រូវទទួលការអនុម័តពីអ្នកគ្រប់គ្រងរបស់យើង។
- ការពារទ្រព្យសម្បត្តិទាំងនេះពីការប្រើប្រាស់មិនត្រឹមត្រូវណាមួយ (ការលួចបន្លំ ការលួច ការបាត់បង់)។

## ៩. សិទ្ធិមនុស្ស និងបទដ្ឋានការងារ៖ លក្ខខណ្ឌការងារប្រកបដោយសមភាព គ្មានការបៀតបៀន គ្មានការរើសអើង

- គោរពយ៉ាងពេញទំហឹងនូវច្បាប់ស្តីពីការងារ និងគោលនយោបាយផ្ទៃក្នុងរបស់ Sika ដែលឆ្លុះបញ្ចាំងពីបទដ្ឋានពលកម្មអន្តរជាតិ។
- មើលការខុសត្រូវអ្នកក្រោមបង្គាប់ និងមិត្តរួមការងារឲ្យស្មើភាព និងជាមួយការគោរព។
- ចូលរួមលើកកម្ពស់គាំទ្រ នូវវប្បធម៌ពិពិធភាព និងបរិយាប័ន្នដោយផ្អែកលើការទុកចិត្ត ដើម្បីសម្រួលដល់ការច្នៃប្រឌិត ដោយការបើកចិត្តទូលាយ និងឱកាសស្មើភាពគ្នា។
- មិនត្រូវប្រព្រឹត្តអំពើមិនត្រឹមត្រូវដាក់អ្នកដទៃ ដោយប្រកាន់លើជាតិសាសន៍ សញ្ជាតិ ភេទ អាយុ សាសនា ឬបៀតបៀនដោយការប្រមាថកាយ វាចា ការបំពាន គំរាមកំហែង ឬបំភិតបំភ័យពួកគេឡើយ។
- មិនត្រូវអត់ឱនចំពោះអាកប្បកិរិយាបំពាន ឬការរើសអើងណាមួយរបស់និយោជិតឡើយ ហើយត្រូវរាយការណ៍ពីការបំពានដែលបានសង្កេតឃើញទៅកាន់អ្នកគ្រប់គ្រង ឬផ្នែកធនធានមនុស្សរបស់អ្នក។

*Sika លើកកម្ពស់បរិយាកាសការងារប្រកបដោយពិពិធភាព និងបរិយាប័ន្ន ដោយនិយោជិតទាំង អស់ប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក ប្រកបដោយសមភាព និង ដោយការគោរព។ Sika ប្តេជ្ញាផ្តល់ឱកាសស្មើៗគ្នា និងហាមឃាត់យ៉ាងតឹងរ៉ឹងនូវការបៀតបៀនផ្លូវភេទ និងការបៀតបៀន ផ្សេងទៀតនៅក្នុងកន្លែងធ្វើការ។*
*Sika ព្យាយាមធានាថាការប្រព្រឹត្តរបស់និយោជិតទាំងអស់ស្របជាមួយបទដ្ឋានសិទ្ធិមនុស្ស ដែលបានព្រមព្រៀងជាអន្តរជាតិ ក៏ដូចជាបទដ្ឋានការងារ និងសង្គមស្នូល និងការគាំទ្រគោលការណ៍ទាំងដប់នៃការព្រមព្រៀងជាសាកលរបស់អង្គការសហប្រជាជាតិ។*
*Sika ប្តេជ្ញាលុបបំបាត់គ្រប់ទម្រង់នៃពលកម្មកុមារ និងពលកម្មដោយបង្ខំ (រួមមានទាសភាពសម័យទំនើប និងការជួញដូរមនុស្ស) ទាំងនៅក្នុងខ្សែសង្វាក់ផលិតកម្មរបស់ខ្លួន និងការប្តេជ្ញាទទួលស្គាល់ សេរីភាពខាងបង្កើតសមាគម ការចរចាជាសមូហភាព និងភាពជាដៃគូសង្គម ការផ្តល់ប្រាក់សំណងសមរម្យ និងម៉ោងធ្វើការត្រឹមត្រូវ។*

** បទដ្ឋានជាសាកលស្តីពីសិទ្ធិមនុស្សរួមមាន សេចក្តីប្រកាសដែលជាគោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិ និងអង្គការពលកម្មអន្តរជាតិ (ILO) សេចក្តីប្រកាសត្រីភាគីស្តីអំពីគោលការណ៍ ទាក់ទងនឹងសហគ្រាសពហុជាតិ និងគោលនយោបាយសង្គម។*

## ១០. ការពារសុវត្ថិភាព សុខភាព និងបរិស្ថាន

- គោរពគោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព សុវត្ថិភាព និងគោលការណ៍ណែនាំផ្ទៃក្នុងដែលពាក់ព័ន្ធ។
- លើកកម្ពស់វប្បធម៌ស្តីពីសុវត្ថិភាព ដោយមិនត្រូវមើលស្រាលលើគោលការណ៍សុវត្ថិភាពនិងការការពារអ្នកដទៃ។
- លើកកម្ពស់ការប្រើប្រាស់ធនធានប្រកបដោយចីរភាព និងចូលរួមក្នុងការអនុវត្តអាជីវកម្ម ប្រកបដោយចីរភាព តាមរយៈការកាត់បន្ថយផលប៉ះពាល់បរិស្ថានដោយ Sika (ការប្រើប្រាស់ថាមពល និងជីវចម្រុះ ខ្យល់ សំណល់ ទឹក) ការរួមចំណែកដល់សេដ្ឋកិច្ចវិលជុំ និងផ្តល់អាទិភាពទៅលើបច្ចេកវិទ្យាដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន។
- មិនត្រូវអនុញ្ញាតឱ្យតម្លៃតបស្នងសេដ្ឋកិច្ចមានអាទិភាពលើការការពារសុវត្ថិភាព សុខភាព និងបរិស្ថានឡើយ។

*សុវត្ថិភាព និងសុខុមាលភាពរបស់និយោជិតគឺអាទិភាពសម្រាប់ Sika។ Sika ដឹកនាំអាជីវកម្មដែលមាននិរន្តរភាព និងទំនួលខុសត្រូវចំពោះសង្គម។ ពិសេស Sika មានទំនួលខុសត្រូវ ក្នុងការអនុលោមយ៉ាងពេញលេញតាមច្បាប់ស្តីពីសុវត្ថិភាព សុខភាព និង ច្បាប់បរិស្ថាន តម្រូវការផ្ទៃក្នុង សម្រាប់ជាប្រយោជន៍របស់និយោជិត អតិថិជន និង សង្គមទាំងមូល និងដើម្បីអនាគត ភពផែនដីរបស់យើង។*




## ១១. ដៃគូអាជីវកម្ម

- ធានាថាអ្នកផ្គត់ផ្គង់ សេវាករ ភ្នាក់ងារ និងអ្នកចែកចាយគោរពតាមវិធានទាំងនេះ។
- អនុលោមតាមវិធានរបស់អតិថិជន ជាពិសេសក្នុងកា។ ផ្តល់អំណោយ និងការអញ្ជើញកម្សាន្ត ទោះបីជាវិធានទាំងនោះតឹងរ៉ឹងជាងក្រមសីលធម៌វិជ្ជាជីវៈនេះ និងគោលការណ៍ស្តីពីអំណោយ និងការអញ្ជើញកម្សាន្តក្នុងតំបន់របស់អ្នកក៏ដោយ។

*Sika រំពឹងថាដៃគូអាជីវកម្ម និង អ្នកផ្គត់ផ្គង់របស់ខ្លួនប្រព្រឹត្តដោយសុចរិតធម៌ និងគោរពតាមក្រមសីលធម៌អាជីវកម្មដូចគ្នា។ ដើម្បីសម្រេចបាននូវគោលដៅនេះ អ្នកផ្គត់ផ្គង់របស់ Sika តម្រូវឱ្យប្រកាន់ខ្ជាប់នូវ**ក្រមសីលធម៌អ្នកផ្គត់ផ្គង់** (Supplier Code of Conduct) ដែល Sika បានកំណត់។ Sika ជួយគាំទ្រអ្នកផ្គត់ផ្គង់របស់ខ្លួនដោយផ្តល់នូវ ការបណ្តុះបណ្តាល និង ការតាមដានការអនុលោមរបស់ពួកគេតាមរយៈកម្រងសំណួរ និង សវនកម្ម។*

## ១២. ការនាំចូល និងការនាំចេញ

- អនុលោមតាមបទប្បញ្ញត្តិជាធរមាន នៃការដាក់ទណ្ឌកម្ម ការមិនរីកសាយភាយអាវុធជាតិផ្ទុះនិងសម្ភារៈគ្រោះថ្នាក់ ការត្រួតពិនិត្យការនាំចេញ-នាំចូល និងបទប្បញ្ញត្តិនៃសារធាតុគ្រោះថ្នាក់។
- ធានាបាននូវការដាក់ប្រតិវេទន៍គយដែលត្រឹមត្រូវ និងទទួលបានរាល់លិខិតអនុញ្ញាតគយ។

*Sika ប្តេជ្ញាអនុវត្តតាមរាល់បទប្បញ្ញត្តិស្តីពីពាណិជ្ជកម្ម និងពន្ធដែលមានជាធរមាន។ ច្បាប់ពាណិជ្ជកម្មជាតិ និងអន្តរជាតិជាច្រើន ធ្វើការរឹតបន្តឹង ឬហាមឃាត់ការនាំចេញ និងនាំចូលផលិតផល ឬសេវាកម្ម។ ការរឹតត្បិតទាំងនេះមិនត្រឹមតែផ្អែកលើលក្ខណៈនៃផលិតផលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្អែកលើប្រទេសដើម ឬប្រទេសគោលដៅ ហើយជួនកាលថែមទាំងផ្អែកលើអត្តសញ្ញាណនៃអតិថិជន និងអ្នកផ្គត់ផ្គង់ ទៀងផង (ការដាក់ទណ្ឌកម្មពាណិជ្ជកម្ម)។*

## ១៣. ការលាងលុយកខ្វក់

- ត្រូវប្រុងប្រយ័ត្ន និងរាយការណ៍ភ្លាមៗទៅថ្នាក់លើរបស់អ្នក ឬអ្នកគ្រប់គ្រងរាល់ប្រតិបត្តិការហិរញ្ញវត្ថុដែលមានភាពមិនប្រក្រតី។

*Sika ប្តេជ្ញាគាំទ្រការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់។ ការលាងលុយកខ្វក់មានន័យថាជាការបញ្ចូលទ្រព្យសម្បត្តិ (មិនមែនត្រឹមតែជាសាច់ប្រាក់) ដែលមានប្រភពពីសកម្មភាពឧក្រិដ្ឋហើយត្រូវបានចរាចរណ៍ធម្មតាទៅក្នុងវដ្តសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការលាងលុយកខ្វក់គឺជាបទឧក្រិដ្ឋ។*

## វិធាននៃការប្រតិបត្តិ

### ១៤. ធានាឲ្យបាននូវការអនុលោមតាមក្រមនេះ

- បុគ្គលិក Sika ទាំងអស់តម្រូវអោយអនុវត្តគោលការណ៍ក្រមសីលធម៌វិជ្ជាជីវៈនេះ ។ រាល់បុគ្គលិកដែលចូលរួមជាមួយ Sika ទាំងអស់តម្រូវអោយគោរពតាម និង យល់ពីសារៈសំខាន់នៃបទបញ្ញត្តិនេះ។
- កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុនស៊ីកាទាំងអស់នឹងត្រូវបានរំលឹកជាទៀងទាត់យ៉ាងហោចណាស់មួយដង ក្នុងមួយឆ្នាំអំពីច្បាប់ទាំងនេះ។
- នាយកគ្រប់គ្រងក្រុមហ៊ុនស៊ីកាទាំងអស់ក៏នឹងត្រូវបានបញ្ជាក់ជារៀងរាល់ឆ្នាំថាក្រុមហ៊ុនដែលពួកគាត់ទទួលខុសត្រូវ បានប្រព្រឹត្តអនុលោមតាមគោលការណ៍ទាំងនេះ
- ផ្នែកគ្រប់គ្រងជាន់ខ្ពស់ (ទីស្នាក់ការកណ្តាល) នឹងធ្វើការបណ្តុះបណ្តាល និងធ្វើសវនកម្មយ៉ាងទៀងទាត់។

*ក្នុងខណៈដែលគណៈគ្រប់គ្រងជាន់ខ្ពស់ នឹងធ្វើការផ្តល់នូវសម្ភារៈ និងវិធីសាស្ត្រចាំបាច់ ការទទួលខុសត្រូវនៃការអនុលោមតាមក្រមសីលធម៌មួយនេះនៅតែបន្តជាបន្ទុករបស់អ្នកគ្រប់គ្រងផ្ទាល់។ ការជ្រើសរើស ការបណ្តុះបណ្តាល និងការគ្រប់គ្រងបុគ្គលិក ដោយសមស្របក៏សំខាន់ដែរនៅក្នុងចំណុចនេះ។*

### ១៥. តម្លាភាពពេញលេញ និងការសម្តែងមតិ

- កត់ត្រា និងពន្យល់រាល់ប្រតិបត្តិការឱ្យបានត្រឹមត្រូវ។
- ជូនដំណឹងដល់ថ្នាក់លើរបស់អ្នកអំពីការប៉ះទង្គិចដែលអាចកើតមានទៅលើគោលការណ៍ទាំងនេះ។
- រាយការណ៍អំពីការបំពានវិធានទាំងនេះ ទៅថ្នាក់លើរបស់អ្នក ផ្នែកធនធានមនុស្ស ឬសមាជិកថ្នាក់គ្រប់គ្រង់តំបន់ ប្រសិនបើគ្មានប្រសិទ្ធភាព ឬមិនអាចធ្វើបាន ត្រូវបញ្ជូនឡើងទៅថ្នាក់គ្រប់គ្រងបន្ទាប់ទៀត។ អ្នកអាចបញ្ជូនឡើងទៅកាន់ផ្នែក Corporate Compliance របស់ក្រុមហ៊ុនតាមរយៈអ៊ីមែល (compliance@ch.sika.com) ឬតាមរយៈបណ្តាញ Sika Trust Line (https://sikatrustline.com)។
- បុគ្គលដែលរាយការណ៍ព័ត៌មានក្នុងគោលបំណងល្អត្រឹមត្រូវ នឹងត្រូវបានទទួលការការពារ និង រក្សាការសំងាត់។អ្នកដែលបំពានលើគោលការណ៍ទាំងនេះនឹងត្រូវទទួលបានការព្រមាន ឬទណ្ឌកម្ម។

*នៅ Sika យើងរក្សាបរិយាកាសបើកទូលាយ និងតម្លាភាពពេញលេញ។ ការបើកចំហអំពីការប៉ះទង្គិចដែលអាចកើតមាន និងអំពីការបំពានគោលការណ៍ នឹងជួយពង្រឹងក្រមសីលធម៌នេះឲ្យកាន់តែមានប្រសិទ្ធភាព។ តម្លាភាពក៏មានសារៈសំខាន់ផងដែរទាក់ទងនឹងការចងក្រងឯកសារ និងការវិភាគពន្យល់គ្រប់ប្រតិបត្តិការទាំងអស់បានត្រឹមត្រូវ ។ យើងលើកទឹកចិត្តឱ្យនិយោជិតទាំងអស់សម្តែងមតិ និងជូនដំណឹងបានត្រឹមត្រូវនិងទាន់ពេលវេលាទៅថ្នាក់លើ ផ្នែកធនធានមនុស្សប្រចាំតំបន់ ឬសមាជិកផ្សេងទៀតនៃគណៈគ្រប់គ្រងប្រចាំតំបន់អំពីហេតុការណ៍សំខាន់ៗ ដោយយោងតាមគោលការណ៍ដែលដាក់ចេញនៅក្នុង **គោលនយោបាយស្តីពីទំនុកចិត្តរបស់** Sika (Sika Trust Policy)។ ការបំពានដែលត្រូវគេចោទប្រកាន់នឹងត្រូវបានស៊ើបអង្កេតយ៉ាងប្រុងប្រយ័ត្ន ប្រសិនបើមានការបញ្ជាក់ នោះនឹងត្រូវទទួលលទ្ធផលជាការព្រមានឬទណ្ឌកម្ម (អាចដល់ថ្នាក់បណ្តេញចេញ ក្នុងករណីសមស្រប) ស្របពេលនោះបុគ្គលដែលរាយការណ៍នឹងត្រូវបានការពារពីការគំរាមគំហែងណាមួយ នៅពេលដែលរាយការណ៍ដោយសុទ្ធចិត្ត និងមានហេតុផលដែលមានមូលដ្ឋានត្រឹមត្រូវ។*

### ១៦. ធ្វើជាគំរូ

- ក្នុងនាមជាអ្នកគ្រប់គ្រង ត្រូវធ្វើការដឹកនាំជាគំរូហើយប្រកាន់ខ្ជាប់នូវក្រមសីលធម៌យ៉ាងតឹងរ៉ឹង។
- ប្រតិបត្តិច្បាប់ដោយគ្មានការយោគយល់នៅក្នុងការទទួលខុសត្រូវរបស់យើង។
- ទទូចឱ្យមានតម្លាភាពដើម្បីដោះស្រាយបានឆាប់នូវហានិភ័យដែលអាចកើតមាន។

*ការរៀបចំឲ្យបានល្អពីខាងលើគឺជាធាតុសំខាន់មួយដើម្បីធានាបានថាក្រមសីលធម៌វិជ្ជាជីវៈនៅតែមានប្រសិទ្ធិភាព។ ការធ្វើជាគំរូ និងការអនុវត្តគោលការណ៍គ្មានការយោគយល់ គឺសំខាន់ណាស់។ វាក៏ជាការបង្កើតបរិយាកាសការងារដែល ការប៉ះទង្គិចដែលអាចកើតឡើង ត្រូវបានដោះស្រាយដោយបើកចំហ និងក្នុងគោលបំណងដើម្បីស្ថាបនា។*



## ១៧. មិនត្រូវធ្វើអ្វីរំលងវិធានទាំងនេះ

- កុំប្រើភាគីទីបីដើម្បីមករំលងច្បាប់ទាំងនេះ

*រាល់ការប្រតិបត្តិ ឬការអនុវត្តអាជីវកម្មសំខាន់ៗគឺមិនអាចផ្ទេរទៅភាគីទីបី (ឧ. ភ្នាក់ងារតំណាងចែកចាយ ទីប្រឹក្សា) ក្នុងគោលបំណងដើម្បីគេចវេសពីច្បាប់ទាំងនេះបានទេ។*

## ១៨. បើមានមន្ទិលសង្ស័យ ត្រូវសួរ

- ត្រូវសួរជានិច្ចបើអ្នកមានមន្ទិលសង្ស័យ។

*ក្នុងករណីជាច្រើន ការបំពានច្បាប់ឬគោលការណ៍ណែនាំផ្ទៃក្នុងអាចចៀសវាងបានដោយសារដំបូន្មាន ដែលទាន់ពេល។ ប្រសិនបើអ្នកមានមន្ទិលសង្ស័យអំពីការសម្រេចចិត្ត ឬសកម្មភាពដែលត្រូវធ្វើ ត្រូវសួរអ្នកដទៃជាមុន និងស្វែងរកដំបូន្មាន ឬជំនួយពីអ្នកគ្រប់គ្រងរបស់អ្នក ឬមុខងារ/ផ្នែកដែលពាក់ព័ន្ធ (ឧ. ផ្នែកធនធានមនុស្ស ផ្នែកច្បាប់ ផ្នែកអនុលោម ឬហិរញ្ញវត្ថុ)។*

## ១៩. គោលការណ៍ទូទៅ៖ ច្បាប់ទស្សនាវដ្ដី

- កន្លែងដែលគ្មានច្បាប់ជាក់លាក់ ឬ បើសិនអ្នកនៅមានការសង្ស័យ សូមត្រួតពិនិត្យការប្រព្រឹត្តរបស់អ្នក ជាមួយនឹងច្បាប់ទស្សនាវដ្ដីដ៏សាមញ្ញមួយ គឺ តើអ្នកនៅតែបន្តប្រព្រឹត្តទេ ប្រសិនបើអ្វីដែលអ្នកធ្វើ នឹងលេចឡើងនៅលើទំព័រមុខនៃទស្សនាវដ្ដីក្នុងប្រទេសរបស់អ្នក ដោយមានព័ត៌មានយ៉ាងលម្អិតពីសកម្មភាពទាំងអស់?

*ក្នុងករណីដែល គោលការណ៍ជាច្រើននៃច្បាប់ទាំងនេះអាចនឹងមានភាពលំអិត ហើយអាចនឹងមិនគ្របដណ្ដប់លើករណីជាក់ស្ដែង នោះច្បាប់ទស្សនាវដ្ដីគឺអាចប្រើប្រាស់បាន និងអាចយល់បានជាសកល។ វាអាចតេស្តភាពទទួលយកបាននៃទង្វើណាមួយ ថាការប្រព្រឹត្តនោះត្រូវបានអនុញ្ញាតឬអត់។*

## ២០. អនុវត្តគោលការណ៍ភ្នែកបួន

- រាល់ការប្ដេជ្ញាចិត្តក្នុងនាម Sika មិនថាត្រូវបានធ្វើឡើងលើក្រដាសស្នាម ឬតាមបែបឌីជីថលទេ ត្រូវតែមានការចុះហត្ថលេខាពីបុគ្គលដែលមានសិទ្ធសម្រេចពីររូប ទោះបីជាច្បាប់ក្នុងតំបន់អនុញ្ញាតឱ្យមានហត្ថលេខាតែមួយក៏ដោយ។
- ប្រសិនបើការប្ដេជ្ញាចិត្តត្រូវបានធ្វើឡើងតាមទំនាក់ទំនងអេឡិចត្រូនិក (អ៊ីមែល សារជាអក្សរ ។ល។) អាចមានចុះហត្ថលេខាពីបុគ្គលម្នាក់បាន។ ទោះជាយ៉ាងនេះក្ដី បុគ្គលទីពីរត្រូវតែត្រួតពិនិត្យ និងយល់ព្រមលើការប្ដេជ្ញាចិត្តនោះមុននឹងធ្វើវាចេញ។
- បើគ្មានការតម្រូវពីច្បាប់ក្នុងតំបន់ទេ មិនត្រូវប្រើត្រាជារូបសញ្ញា តែមស៍ផ្ទាល់ខ្លួនទេ ប្រសិនបើប្រើត្រាជារូបសញ្ញា តែមស៍ ត្រូវបន្ថែមហត្ថលេខាផ្ទាល់ខ្លួនជានិច្ច។

*គោលការណ៍ភ្នែកបួន គឺជាគោលការណ៍សំខាន់របស់ Sika សម្រាប់ការអនុវត្តក្រមសីលធម៌ វិជ្ជាជីវៈនិងការគ្រប់គ្រងហានិភ័យដែលសមស្រប។ អ្នកទីពីរដែលមានសមត្ថភាពត្រូវពិនិត្យឡើងវិញរាល់បញ្ហាអាជីវកម្មដើម្បីឱ្យប្រាកដថាការសម្រេចចិត្តនេះត្រឹមត្រូវ និងជាពិសេសអនុលោមតាមក្រមសីលធម៌នេះ។*

## ២១. សំណួរ និងយោបល់

ប្រសិនបើអ្នកមានមន្ទិលសង្ស័យ ឬមានចម្ងល់ទាក់ទងនឹងក្រមសីលធម៌វិជ្ជាជីវៈនេះ សូមទាក់ទងថ្នាក់លើរបស់អ្នក ឬក្រុមហ៊ុន។ អ្នកអាចនឹងធ្វើសំណួរ និងផ្ដល់យោបល់ផងដែរទៅតាមអាសយដ្ឋាន: compliance@ch.sika.com.





# ក្រមសីលធម៌

## ភាពសុចរិតនិងការប្រព្រឹត្តប្រកបដោយសីលធម៌

BUILDING TRUST